ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ១២៨៧ ចុះថ្ងៃទី ២៥.១២.២០១៥

សំណុំរឿងជំនុំជម្រះលេខ: ២៦៨ ចុះថ្ងៃទី ០៧.០៥.២០១៦

សាលក្រមលេខ: ៣១ "ជ"

ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៦

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តសៀមរាប បានបើកសវនាការជាសាធារណៈ នៅនាទីសាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ២ កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦ វេលាព្រឹក កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦វេលាព្រឹក

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១២៨៧ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥ និងសំណុំរឿងជំនុំជម្រះលេខ: ២៦៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៣.០៩.១៩៨០ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅស្រុកស្រីស្នំ ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរម៉ូតូឌុប ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន មាន (ធ្លាប់ជាប់ពន្ធនាគារចំនួន ៣ឆ្នាំ ពីរឿងគ្រឿងញៀន) ។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៦.១២.២០១៥ ។

ត្រូវជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៣ និងថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

២- ឈ្មោះ [redacted] ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ១៥.០៥.១៩៩៦ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរអ៊ុតសក់ នៅលីវ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៦.១២.២០១៥ ។

៣- ឈ្មោះ [redacted] ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិធំ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិអង្គទ្វារ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរគ្មាន កំរិតវប្បធម៌ ថ្នាក់ទី ៨ថ្មី នៅលីវ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](ស) ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៦.១២.២០១៥ ។

៤- ឈ្មោះ [redacted] ភេទស្រី អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម មានទីលំនៅមុនពេលចាប់ខ្លួនស្នាក់នៅបន្ទប់ជួលភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរលក់គ្រឿងអនុស្សាវរីយ៍ នៅលីវ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៦.១២.២០១៥ ។

ត្រូវជាប់ចោទពីបទ: **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និងថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដោយមានលោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]

៥- ឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រពាំងឈើង សង្កាត់ត្រពាំងថ្លឹង ខណ្ឌដង្កោ រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាក្រាញ់ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរអ្នកបើកឡាន ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន។ (ក្រៅឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ដោះលែងឲ្យនៅក្រៅឃុំថ្ងៃទី ១៦.០៣.២០១៦ ។



Scanned by CamScanner

៦- ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិបន្លាស្អិត សង្កាត់ខ្វាញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិភ្នំក្រោម សង្កាត់ចុងឃ្នៀស ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរជាសិស្ស កំរិតវប្បធម៌ថ្នាក់ទី ១១ថ្មី នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) ទោសពីមុនគ្មាន។ (ក្រៅឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៥.១២.២០១៥ ។
- ដោះលែងឲ្យនៅក្រៅឃុំថ្ងៃទី ១២.០២.២០១៦ ។

ត្រូវជាប់ចោទពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៣ និងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] , ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted]។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៥៤ ពស.ព្រទ ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។
- បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១១១០ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៣៥០ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**៦អង្គហេតុកើតមានឡើងដូចតទៅ**

កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើសកម្មភាពចុះបង្ក្រាបករណីជួញដូរគ្រឿងញៀន ពេលចុះទៅដល់ចំណុចកើតហេតុស្ថិតនៅក្នុងភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដោយបានឃាត់ខ្លួនឈ្មោះ [redacted] កំពុងធ្វើសកម្មភាពជួញដូរគ្រឿងញៀន។ ពេលឃាត់ខ្លួននោះឈ្មោះ [redacted] ានសារភាពថា " ថ្នាំញៀននោះជារបស់ឈ្មោះ [redacted] ដោយខ្លួនបានទិញក្នុងតំលៃ ៣០$ (សាមសិប) ដុល្លាអាមេរិក ហើយឈ្មោះ [redacted] បានប្រើខ្លួនយកទៅឲ្យគេនៅក្រោយវត្តបូព៌" ។ ក្រោយមកទៀតនៅថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ សមត្ថកិច្ចក៏បានបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] និងឈ្មោះ [redacted] នៅពេលដែលពួកគេបានជិះម៉ូតូមកទិញថ្នាំញៀនយកមកនៅម្តុំស្ពាននាគ តែមិនទាន់បានយកថ្នាំផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។បន្ទាប់មកសមត្ថកិច្ចក៏បានបន្តឃាត់ខ្លួនឈ្មោះ [redacted] [redacted] និងឈ្មោះ [redacted] នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ នៅចំណុចវត្តថ្មីដោយសារមានការសង្ស័យពាក់ព័ន្ធទៅនិងរឿងគ្រឿងញៀន។ ចុងក្រោយសមត្ថកិច្ចបានចុះស្រាវជ្រាវ ហើយឃាត់ខ្លួនឈ្មោះ [redacted] នៅពេលដែលឈ្មោះនេះបានដើរទៅទិញថ្នាំញៀនពីឈ្មោះ: [redacted]



Scanned by CamScanner

ត្រូវជាមិត្តភក្តិ ហើយឈ្មោះ [redacted] បានប្រើខ្លួនឲ្យយកថ្នាំញៀនទៅលក់ឲ្យមនុស្សប្រុសម្នាក់មិនស្គាល់មុខក្នុងតម្លៃ ១០$ (ដប់) ដុល្លាអាមេរិក ពេលទៅដល់ជិតផ្លូវបំបែកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

<u>សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាដេញដោល</u>

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមតុលាការជួយបន្ធូរបន្ថយទោសដោយក្តីអនុគ្រោះ ។

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមតុលាការជួយបន្ធូរបន្ថយទោសដោយក្តីអនុគ្រោះ។

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមតុលាការដោះលែងឲ្យមានសេរីភាព ដើម្បីមើលថែរក្សាម្តាយចាស់ជរា ។

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមឲ្យតុលាការជួយបន្ធូរបន្ថយទោស ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ១៥៤ ពស.ព្រទ ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងខេត្ត សៀមរាប និងប្តឹងសុំឲ្យលោកចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានដោះលែងឲ្យនៅក្រៅឃុំ ហើយបានកែប្រែខ្លួនសុំឲ្យតុលាការអនុវត្តទោសត្រឹមតែការឃុំខ្លួនបានហើយ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ពុំបានប្រើប្រាស់ថ្នាំញៀនទេ គឺគ្រាន់តែទៅយកទូរស័ព្ទពីឈ្មោះ [redacted] ហើយក៏ចាប់ខ្លួនធ្វើតេស្តទឹកនោម ឃើញថាមានសារធាតុញៀនពុំមែនភស្តុតាងណាមួយថាឈ្មោះ [redacted] ចាត់ចែងឲ្យប្រើប្រាស់ថ្នាំញៀនទេ ហេតុនេះសូមតុលាការសំរេចឲ្យជនជាប់ចោទឈ្មោះ [redacted] រួចខ្លួនពីបទចោទ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] បានសារភាពនូវទង្វើប្រព្រឹត្តរបស់គាត់ ហើយគាត់បានសហការជាមួយសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទជាច្រើននាក់ថែមទៀត ។ តាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនត្រូវបន្ថយទោសពាក់កណ្តាល។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ខ្លួនសុំរក្សាសេចក្តីសន្និដ្ឋានរបស់សហភាគខ្លួន គឺលោក [redacted] ទុកជាបានការដែរ ។



Scanned by CamScanner

- លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បាន
ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ជនជាប់ចោទឈ្មោះ [redacted] ប់ពីបទប្រើប្រាស់ដោយខុស
ច្បាប់នូវសារធាតុញៀន ជនជាប់ចោទជាក្មេងកំព្រាគ្មានឪពុកម្តាយ , គ្មានការអប់រំ , អវិជ្ជា ពុំបាន
ស្តាប់នូវព័ត៌មានពីការប្រើប្រាស់គ្រឿងញៀនជាអំពើខុសច្បាប់ ហេតុនេះសូមតុលាការផ្តល់ស្ថាន
សម្រាលទោសតាមបញ្ញត្តិមាត្រា ១៦០ និងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ។

<u>ផ្អែកតាមកិច្ចពិភាក្សាដេញដោល</u>

ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យគស្តុតាងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាល
យុត្តិធម៌។

ក្រោយពីបានស្តាប់ការកត់សម្គាល់របស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់

<u>**សំអាងហេតុ**</u>

- កាលពីថ្ងៃទី ២៣ និងថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ នៅក្រុងសៀមរាប ខេត្តសៀមរាប
ពិតជាមានអំពើ *ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* បានកើតឡើង បង្កឡើងដោយ
ជនជាប់ចោទ ឈ្មោះ [redacted] និងពិតជាមានអំពី *ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវ
សារធាតុញៀន* បានកើតឡើង បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] . ឈ្មោះ
[redacted] និងឈ្មោះ [redacted] ព្រមទាំងមានអំពើ *ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុ
ញៀន* បានកើតឡើង បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ
[redacted] ប្រាកដមែន ។

- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា: សមត្ថ
កិច្ចឃាត់ខ្លួនខ្ញុំនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ៨ម៉ោង៣០នាទីយប់ នៅមុំវត្តថ្មី ក្រុង
សៀមរាប ខេត្តសៀមរាប ។ ដោយសារកាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ប្រហែលម៉ោង២
ជិតពារសៀល មានឈ្មោះ [redacted] បានទូរស័ព្ទមកខ្លួន ហើយនិយាយថា គេឲ្យទូរស័ព្ទមកខ្លួនមួយ
គ្រឿង ដោយផ្ញើទុកនឹងប្អូនរបស់គាត់ដោយឲ្យខ្លួនទៅយកពីប្អូនរបស់គាត់ ។ ហើយនៅថ្ងៃទី
២៥ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ៨ម៉ោង៣០នាទីយប់ ខ្លួនក៏បានបបួលឈ្មោះ [redacted] ភេទស្រី
ឲ្យមកជាមួយ ពេលដែលខ្លួនជិះទៅដល់មុខវត្តថ្មី ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនទាំងពីរនាក់តែម្តង។
ខ្លួនមិនដែលស្គាល់ប្អូនរបស់ឈ្មោះ [redacted] នោះទេ ។ ខ្លួនធ្លាប់ជក់ថ្នាំញៀនបានចំនួន៤ ទៅ៥ដង
ជក់ជាមួយមិត្តភក្តិ ខ្លួនពុំធ្លាប់លក់ដូរថ្នាំញៀននោះឡើយ។ ចម្លើយសារភាពនេះ មានហេតុផល
សមរម្យអាចឲ្យតុលាការជឿបាន ។



Scanned by CamScanner

- ពេលសួរនាំការជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា: សមត្ថ
កិច្ចឃាត់ខ្លួនៗនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ១២យប់ ស្ថិតនៅផ្លូវបំបែកវត្តចក។
ពេលនោះខ្លួនកំពុងតែដើរយកគ្រឿងញៀនឲ្យឈ្មោះ [redacted] ត្រូវជាមិត្តភក្តិរបស់ខ្លួន។ ឈ្មោះ [redacted]
បានប្រើខ្លួនឲ្យទៅយកថ្នាំញៀនពីមនុស្សប្រុសមិនស្គាល់ឈ្មោះ កាន់លេខទូរស័ព្ទមិនចាំ។ ខ្លួន
ទៅយកថ្នាំញៀននោះ ឈ្មោះ [redacted] បានឲ្យលុយខ្លួនចំនួន ១០$ (ដប់)ដុល្លាអាមេរិក ហើយយក
ថ្នាំមិនទាន់បានផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនពុំទាន់ទិញថ្នាំញៀនពីអ្នកណានោះទេ
គឺទើបតែលើកទីមួយនេះឯង។ ខ្លួនធ្លាប់ជក់ថ្នាំញៀនបានមួយខែហើយ គឺជក់ជាមួយឈ្មោះ [redacted]
តែពីរនាក់ទេ។ ថ្នាំដែលជក់ គឺប្រភេទម៉ាទឹកកក ហើយថ្នាំទាំងនោះឈ្មោះ [redacted] ជាអ្នកទិញ
ខ្លួនមិនដឹងរកទិញពីអ្នកណានោះទេ។ ខ្លួនមិនដឹងឈ្មោះ [redacted] មានអាសយដ្ឋាននៅឯណានោះ
ទេ ។ ចម្លើយសារភាពនេះ មានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសួរនាំការជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា: សមត្ថ
កិច្ចឃាត់ខ្លួនៗនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ១២យប់ នៅវត្តគោកចក។ ដោយ
សារខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ដោយសារគាត់ខ្ចីម៉ូតូរបស់ខ្លួនជិះទៅញ៉ាំ
បង្អែម តែខ្លួនមិនទុកចិត្តក៏ខ្លួនទៅជាមួយគាត់នៅពេលទៅដល់មុខវត្តគោកចក ក៏ត្រូវសមត្ថកិច្ច
ឃាត់ខ្លួនទាំងពីរនាក់តែម្តង ដោយសារសង្ស័យថាពួកខ្លួនមានពាក់ព័ន្ធគ្រឿងញៀន។ ខ្លួនធ្លាប់
ប្រើប្រាស់ថ្នាំញៀនបានចំនួន ៥ទៅ៦ដងហើយ តែខ្លួនឈប់ប្រើយូរហើយ។ ខ្លួនមិនដែលបាន
លក់ដូរថ្នាំញៀននោះទេ ហើយសមត្ថកិច្ចឃាត់ខ្លួន បានដកហូតម៉ូតូរបស់ខ្លួនចំនួន០១គ្រឿង។
ចម្លើយសារភាពនេះមានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសួរនាំការជនជាប់ចោទឈ្មោះ [redacted] វត្តមាន) តែតាមចម្លើយនៅដំណាក់
កាលចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថា: សមត្ថកិច្ចឃាត់ខ្លួនៗនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥
វេលាម៉ោង ១២យប់ ស្ថិតនៅម៉ុំស្ពាននាគ នៅថ្ងៃកើតហេតុខ្លួនចេញពីធ្វើការ ហើយទៅមើលគេ
តាំងពីពណ៌នៅព្យុងយូរដោយជិះម៉ូតូជាមួយក្មួយប្រុសឈ្មោះ [redacted]។ បន្ទាប់
មកនៅម៉ោងប្រហែល ១២យប់ ទើបខ្លួនមកម៉ុំស្ពាននាគ ដោយក្មួយប្រុសបានបបួលខ្លួនជក់ថ្នាំ
ញៀន ពេលនោះក្មួយប្រុសខ្លួនបានទូរស័ព្ទទៅអ្នកលក់ថ្នាំញៀន ដើម្បីឲ្យគេយកមកឲ្យ ។ នៅ
ពេលនោះសមត្ថកិច្ចបានឃាត់ខ្លួនៗតែម្តង ដោយមិនទាន់បានថ្នាំញៀនផង ។ ខ្លួនមិនធ្លាប់ទិញ
លក់ថ្នាំញៀនទេ តែធ្លាប់ប្រើប្រាស់ថ្នាំញៀននៅភ្នំពេញបានប្រហែល០៣ដង ។ សមត្ថកិច្ចឃាត់
ខ្លួនៗ និងឆែកឆេរខ្លួនមិនឃើញថ្នាំញៀននោះទេ។ ចម្លើយសារភាពនេះ មានហេតុផលសម
រម្យអាចឲ្យតុលាការជឿបាន។

- ពេលសួរនាំការជនជាប់ចោទឈ្មោះ [redacted] វត្តមាន) តែតាមចម្លើយ
នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថា: សមត្ថកិច្ចឃាត់ខ្លួនៗនៅម៉ុំស្ពាននាគ
ដោយសារខ្លួនទូរស័ព្ទទិញថ្នាំញៀនពីមនុស្សប្រុសមិនស្គាល់ឈ្មោះ មិនស្គាល់លេខទូរស័ព្ទ ។
ខ្លួនទិញថ្នាំញៀនចំនួន ៣០០០០៛ (បីម៉ឺន)រៀល ប្រភេទម៉ាទឹកកក មិនទាន់បានថ្នាំផងក៏ត្រូវ



Scanned by CamScanner

សមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ពេលនោះពូរបស់ខ្លួនឈ្មោ[redacted]គជាមួយខ្លួនដែរ ហើយគាត់ក៏បានដឹងថាខ្លួនទូរស័ព្ទទៅទិញថ្នាំញៀនដែរ ។ ហើយគាត់ក៏មានបំណងចង់ជក់ថ្នាំញៀនជាមួយខ្លួនដែរ ។ ដោយពូរបស់ខ្លួនមិនបានហាមឃាត់ថាកុំឲ្យទិញថ្នាំញៀននោះទេ។ កន្លងមកពូរបស់ខ្លួនមិនដែលបានជក់ថ្នាំញៀនជាមួយខ្លួននោះឡើយ។ ចម្លើយសារភាពនេះ មានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបដិសេធថា: សមត្ថកិច្ចខ្លួនៗដោយសារកាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ៨ម៉០០នាទី ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ [redacted] "មិនស្គាល់នាមត្រកូល និងអាសយដ្ឋាន" ចំនួន០១កញ្ចប់តូច ក្នុងតំលៃ៣០$ (សាមសិប) ដុល្លាអាមេរិក នៅក្រោយផ្សារលើធំថ្មី ដើម្បីយកទៅប្រើប្រាស់។ ពេលនោះស្រាប់តែមានគេទូរស័ព្ទចូលមកទូរស័ព្ទរបស់ឈ្មោ[redacted] ហើយឈ្មោះ[redacted]បានប្រើខ្លួនឲ្យជួយយកថ្នាំ០១កញ្ចប់តូច យកទៅឲ្យគេនៅក្រោយវត្តបូព៌។ ខ្លួន " មិនស្គាល់ឈ្មោះម្នាក់នោះ និងភ្លេចលេខទូរស័ព្ទ" ពេលនោះខ្លួនក៏បានទាក់ទងទៅគេ ដើម្បីយកថ្នាំឲ្យ។ នៅពេលខ្លួនទៅដល់ក្រោយវត្តបូព៌ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនធ្លាប់លក់ដូរថ្នាំញៀនទេធ្លាប់តែជក់បានចំនួន ០៣ដង ជក់តែម្នាក់ឯងទេ។ ចម្លើយដោះសារនេះ មិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការជឿបានទេ ។

- តាមរបាយការណ៍សរុបលេខ: ១០៩ / ០១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ការិយាល័យស្រាវជ្រាវប្រឆាំងបទល្មើសគ្រឿងញៀន នៃបញ្ជាការដ្ឋានកងរាជអាវុធខេត្តសៀម-រាប បានបញ្ជាក់ថា៖ ឈ្មោ[redacted] ឈ្មោ[redacted] ឈ្មោះ [redacted] ពិតជាបានធ្វើសកម្មភាពចាត់ចែងឲ្យប្រើប្រាស់នូវសារធាតុញៀន និងឈ្មោះ[redacted],ឈ្មោះ [redacted]ពិតជាបានធ្វើសកម្មភាពប្រើប្រាស់នូវសារធាតុញៀន ព្រមទាំងឈ្មោះ [redacted]ពិតជាបានធ្វើសកម្មភាពជួញដូរនូវសារធាតុញៀនប្រាកដមែន។

-ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយបដិសេធ តែតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោ[redacted] ឈ្មោះ [redacted], ឈ្មោ[redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] មានលក្ខណៈស៊ីសង្វាក់ទៅនឹងភស្តុតាងដែលសមត្ថកិច្ចដកហូតបានព្រមទាំងឯកសារដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់ថា៖ កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើសកម្មភាពចុះបង្ក្រាបករណីជួញដូរគ្រឿងញៀនពេលចុះទៅដល់ចំណុចកើតហេតុស្ថិតនៅក្នុងភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដោយបានឃាត់ខ្លួនឈ្មោ[redacted]កំពុងធ្វើសកម្មភាពជួញដូរគ្រឿងញៀន។ ពេលឃាត់ខ្លួននោះឈ្មោះ [redacted]បានសារភាពថា " ថ្នាំញៀននោះជារបស់ឈ្មោះ [redacted] ដោយខ្លួនបានទិញក្នុងតំលៃ ៣០$ (សាមសិប) ដុល្លាអាមេរិក ហើយឈ្មោះ[redacted]បានប្រើខ្លួនយកទៅឲ្យគេនៅក្រោយវត្តបូព៌"។ ក្រោយមកទៀតនៅថ្ងៃ២៤ ខែធ្នូ ឆ្នាំ២០១៥ សមត្ថកិច្ច



Scanned by CamScanner

កំបានបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] និងឈ្មោះ [redacted] ពេលដែលពួកគេបានជិះម៉ូតូមកទិញថ្នាំញៀនយកមកនៅម៉ុស្តាននាគ តែមិនទាន់បានយកថ្នាំផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ បន្ទាប់មកសមត្ថកិច្ចក៏បានបន្តឃាត់ខ្លួនឈ្មោះ [redacted] ងឈ្មោះ [redacted] នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ នៅចំណុចវត្តថ្មីដោយសារមានការសង្ស័យពាក់ព័ន្ធទៅនិងរឿងគ្រឿងញៀន។ ចុងក្រោយសមត្ថកិច្ចបានចុះស្រាវជ្រាវ ហើយឃាត់ខ្លួនឈ្មោះ [redacted] នៅពេលដែលឈ្មោះនេះបានដើរទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ត្រូវជាមិត្តភក្តិ ហើយឈ្មោះ [redacted] បានប្រើខ្លួនឲ្យយកថ្នាំញៀនទៅលក់ឲ្យមនុស្សប្រុសម្នាក់មិន ស្គាល់លក់ក្នុងតំលៃ ១០$ (ដប់)ដុល្លាអាមេរិកពេលទៅដល់ជិតផ្លូវបំបែកវត្តចកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តងព្រាកដមែន។

- ជនជាប់ចោទឈ្មោ [redacted] មានចេតនាទុច្ចរិត ដោយបានធ្វើសកម្មភាពទិញលក់នូវសារធាតុញៀនដែលច្បាប់បានហាមឃាត់ ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ: *ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- ជនជាប់ចោទឈ្មោ [redacted] ឈ្មោះ [redacted] ងឈ្មោះ [redacted] មានចេតនាទុច្ចរិត ដោយបានធ្វើសកម្មភាពចាត់ចែងឲ្យប្រើប្រាស់នូវសារធាតុញៀន ដែលច្បាប់បានហាមឃាត់ ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ: *ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន* ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោ [redacted] ានចេតនាទុច្ចរិត ដោយបានធ្វើសកម្មភាពប្រើប្រាស់នូវសារធាតុញៀន ដែលច្បាប់បានហាមឃាត់ ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ: *ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន* ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ: ១៥៤ ពស.ព្រទ ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្តឹងសុំឲ្យផ្តន្ទាទោសតាមច្បាប់ ។

- សេចក្តីសន្និដ្ឋានរបស់លោ [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] លបានស្នើសុំ៖ ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានដោះលែងឲ្យនៅក្រៅឃុំ ហើយបានកែប្រែខ្លួនសុំឲ្យតុលាការអនុវត្តទោសត្រឹមតែការឃុំខ្លួនបានហើយ ។ ចំពោះ ជនជាប់ចោទឈ្មោះ [redacted] បានប្រើប្រាស់ថ្នាំញៀនទេ គឺគ្រាន់តែទៅយកទូរស័ព្ទពីឈ្មោ [redacted] ហើយក៏ចាប់ខ្លួនធ្វើតេស្តទឹកនោម ឃើញថាមានសារធាតុញៀនពុំមានភស្តុតាង

ណោះឲ្យឃើញថាឈ្មោះ [redacted]ាត់ចែងឲ្យប្រើប្រាស់ថ្នាំញៀនទេ ហេតុនេះសូមតុលាការសំរេចឲ្យជនជាប់ចោទឈ្មោះ [redacted]ចខ្លួនពីបទចោទ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] បានសារភាពនូវទង្វើប្រព្រឹត្តរបស់គាត់ ហើយគាត់បានសហការជាមួយសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទជាច្រើននាក់ថែមទៀត ។ តាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនត្រូវបន្ថយទោសពាក់កណ្តាល។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted]ាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ដែលបានស្នើសុំ៖ ខ្លួនសុំរក្សាសេចក្តីសន្និដ្ឋានរបស់សហជាតខ្លួន គឺលោក [redacted] ទុកជាបានការដដែល ។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ដែលបានស្នើសុំ៖ ជនជាប់ចោទឈ្មោះ [redacted]ជាប់ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ជនជាប់ចោទជាក្មេងកំព្រាគ្មានឪពុកម្តាយ , គ្មានការអប់រំ , អវិជ្ជា ពុំបានស្តាប់នូវព័ត៌មានពីការប្រើប្រាស់គ្រឿងញៀនជាអំពើខុសច្បាប់ ហេតុនេះសូមតុលាការផ្តល់ស្ថានសម្រាលទោសតាមបញ្ញត្តិមាត្រា ១៦០ និងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ។

- ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និង ឈ្មោះ [redacted]សុទ្ធតែជាជនពុំមានបញ្ហាខាងស្មារតីឡើយ ជនជាប់ចោទពិតជាបានយល់ដឹងពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន។

- ជនជាប់ចោទឈ្មោះ [redacted]អាយុ ១៥ឆ្នាំ និងឈ្មោះ [redacted] អាយុ ១៦ឆ្នាំ ជាអនីតិជន ពុំមានសញ្ញាណណាមួយបញ្ជាក់ពីបញ្ហាស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះទេ។

\+ *ក្រោយពីបានពិនិត្យពិចារណាលើកស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគីតុលាការប្រកាសថា ៖*

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ឈ្មោះ [redacted]និងឈ្មោះ [redacted]បទ: **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ



Scanned by CamScanner

២០១៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើឲ្យប៉ះពាល់ដល់សុខភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

- វត្ថុចាប់យកដូចមាននៅក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុដែលចាប់យកលេខ: ៨១ វត/ព្រទ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ មានដូចជា ៖

ក- ស្រោមសំបុត្របិទជិតពណ៌សដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] និងហត្ថលេខារបស់លោក [redacted] គឺជាវត្ថុតាងនៃបទល្មើស គប្បីសម្រេចរឹបអូស និងបំផ្លាញចោល។ តាមមាត្រា ៨៤ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ទូរស័ព្ទដៃចំនួន ០៦ (ប្រាំមួយ) គ្រឿង រួមមាន៖ ទូរស័ព្ទដៃម៉ាក IPHONE IMEI-0133 35006289156 ពណ៌មាស (បែកអេក្រង់) ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក OPPO ពណ៌ស ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខ្មៅ ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខៀវលាយខ្មៅ ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខ្មៅ ចំនួន ០១គ្រឿង និងទូរស័ព្ទដៃម៉ាក NOKIA MODEL : 100 ពណ៌ខ្មៅលាយសលាយទឹកសមុទ្រ ចំនួន ០១គ្រឿង គឺជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន មិនមែនជាវត្ថុតាងនៃបទល្មើសទេ គប្បីសម្រេចប្រគល់ឲ្យទៅម្ចាស់ដើមវិញ។ តាមមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៥៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១- ផ្តន្ទាទោស៖

ក- ឈ្មោះ [redacted] ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៣.០៥.១៩៨០ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២ (ពីរ)ឆ្នាំ ។

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

ខ- ឈ្មោះ [redacted] ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ១៤.០៩.១៩៨៥ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ៦(ប្រាំមួយ)ខែ ។

គ- ឈ្មោះ [redacted] ភេទប្រុស (អនីតិជន) អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ៣(បី)ខែ ។

ឃ- ឈ្មោះ [redacted] ភេទស្រី អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ៣(បី)ខែ ។

ពីបទៈ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ កថាខណ្ឌ ១ ចំណុច ១,៤ នៃក្រមព្រហ្មទណ្ឌ ។

ង- ឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ)ខែ ។

ច- ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (អនីតិជន) ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ)ខែ ។

ពីបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ កថាខណ្ឌ ១ ចំណុច ១,៤ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុចាប់យកដូចមាននៅក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុដែលចាប់យកលេខ:៨១ វត/ព្រទ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ មានដូចជា ៖

ក- ស្រោមសំបុត្របិទជិតពណ៌សដែលមានស្នាមមេដៃរបស់ឈ្មោ [redacted] ងហត្ថលេខារបស់លោក [redacted] <u>សម្រេចរឹបអូស</u> ។ មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ទូរស័ព្ទដៃចំនួន ០៦ (ប្រាំមួយ) គ្រឿង រួមមាន៖ ទូរស័ព្ទដៃម៉ាក IPHONE IMEI-0133 35006289156 ពណ៌មាស (បែកអេក្រង់) ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក OPPO ពណ៌ស ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខ្មៅ ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខៀវលាយខ្មៅ ចំនួន ០១គ្រឿង , ទូរស័ព្ទដៃម៉ាក NOKIA MODEL : 105 ពណ៌ខ្មៅ ចំនួន ០១គ្រឿង និងទូរស័ព្ទដៃម៉ាក NOKIA MODEL : 100 ពណ៌ខ្មៅលាយសលាយទឹកសមុទ្រ ចំនួន ០១គ្រឿង <u>**សម្រេចប្រគល់ឲ្យទៅម្ចាស់ដើមវិញ**</u>។ តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned by CamScanner

៣- សាលក្រមនេះពំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] , ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

- ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់៕

| | |
|---|---|
| ក្រឡាបញ្ជីអង្គសវនាការ | ចៅក្រមជំនុំជម្រះ |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| សៀមរាប , ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៦ | សៀមរាប , ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៦ |
| ចៅក្រមជំនុំជម្រះ | ក្រឡាបញ្ជី |
| | [redacted] |



Scanned by CamScanner